ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង
# រវាង
# តំណាងកម្មករនិយោជិត និងសហជីពនៃសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់
# និង
# ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី១៣ ខែកញ្ញា ឆ្នាំ២០២១ រវាងសហជីពនិយោជិតទេសចរណ៍អាស៊ាននៃសណ្ឋាគាររ៉ាហ្វលឡឺរ៉ូយ៉ាល់(ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Hotel Le Royal កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃកូរ៉ូណាវីរុសទូទាំងពិភពលោកបាននាំមកនូវ ការបញ្ឈប់ការ ធ្វើដំណើរអន្តរជាតិទាំងអស់ ហេតុដូចនេះហើយសណ្ឋាគារកំពុងតែជួបប្រទះនូវកម្រិតអាជីវកម្មដែលមិនស្ថិតស្ថេរ។ ដូច្នេះ និយោជក និងសហជីពបានធ្វើការចរចានិងព្រមព្រៀងលើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៤នាក់ (ស្រី ៦នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២៤១នាក់ (ស្រី ៨៧នាក់) រយៈពេល ៩ថ្ងៃ ដោយគិតចាប់ពី ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ គូភាគីបានព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

- និយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារបណ្តោះអាសន្ននឹងទទួលបានប្រាក់ឈ្នួល ៧៥% នៃប្រាក់ខែគោលរបស់ពួកគេ និងប្រាក់ធានានុគ្រោះ។
- ការព្យួរកិច្ចសន្យាការងារបណ្តោះអាសន្ននឹងត្រូវបានផ្តល់អាទិភាពដោយផ្អែកលើអតីតភាពការងាររបស់និយោជិត តាមផ្នែកនីមួយៗ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់នឹងបន្តធម្មតា
- អតីតភាពការងារនឹងមិនត្រូវបានប៉ះពាល់

ព្រះរាជាណាចក្រកម្ពុជា Raffles Royal Hotel Pte., Ltd. សណ្ឋាគាររាជធានីភ្នំពេញ

គូភាគីព្រមព្រៀងដោយផ្តិតមេដៃខាងក្រោមនេះ៖

ភាគី តំណាងកម្មករនិយោជិត និងសហជីព

ប៊ុន ឈឿន
ប្រធាន

ស៊ូ សារ៉ុន
អនុប្រធាន

យ៉ស់ ចាន់ថុល
លេខាធិការ

ភាគីនិយោជក

រាជធានីភ្នំពេញ ថ្ងៃទី.13.. ខែ .កក្កដា.... ឆ្នាំ២០២១
ហត្ថលេខា និងត្រា
នាយកសណ្ឋាគារ

Raffles Royal Hotel
Pte., Ltd.

Dennis de Groot